BIBLIOTHÈQUE
NATIONALE
DU CAMBODGE
P.K_1
1942 (11-12)

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែ ១ ក្បាល

ឆ្នាំទី ១៤ ភាគទី ១១-១២

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ
បានអនុញ្ញាតហើយ

ភ្នំពេញ
ការផ្សាយរបស់ព្រះរាជបណ្ណាល័យ
ព.ស. ២៤៨៥
គ.ស. ១៩៤២

# បញ្ជីរឿង


ទំព័រ

១ — វិទ្យុធម្មទេសនា កណ្ឌទី ៥ លោកគ្រូអាចារ្យ ម៉ុញ-តាំត្រី ក្រុមជំនុំព្រះត្រៃបិដក នៅក្រសួងពុទ្ធសាសនបណ្ឌិត្យ សំរើង . . . . . . . . . . . . . . . . ១

២ — សេចក្ដីផ្សេងៗ . . . . . . . . . . . . . . . . . . . . . . . . ១២

៣ — លោកខេយ្យ ពាក្យកាព្យ របស់នាកញ្ញាវង្សាសពេជ្ញ ផង (តមក) . . . . . ២០

៤ — រឿងព្រះបាទអសោកមហារាជ អ្នកអាចារ្យ គឹម-អាន ប្រែពីបារាំងសេសមក-ជាខេមរភាសា (តមក) . . . . . . . . . . . . . . . . . . . . ២៧

៥ — ពង្សាវតារក្រុងរោម ស្រង់យកពីគោលបារីកផ្សេងៗ ក្នុងពង្សាវតារលោក (តមក) . . . . . . . . . . . . . . . . . . . . . . . . ៣៣

៦ — ភូមិសាស្ត្រសង្ខេបនៃប្រទេសនានាៈ អំពីភូមិសាស្ត្រទ្វីបអាមេរិកខាងជើង. . . . ៤១

៧ — ប្រវត្តិពួកឧបាសក-ឧបាសិកា ជាសាវក-សាវិការបស់ព្រះពុទ្ធជាម្ចាស់ : ទី ៩ ប្រវត្តិជីវកកោមារភច្ច ទី ១០ ប្រវត្តិនកុលបិតាគហបតិ . . . . . . . . . . . ៤៨

៨ — ប្រស្នាបំភ្លឺសតិបញ្ញាៈ ប្រស្នាទទី ២ សួរនិងឆ្លើយអំពីទ្វាក់នឹងទិន . . . . . . ៥១

៩ — រឿងព្រេងខ្មែរៈ " រឿងចៅម្ចាស់ផ្ទះនឹងចៅសុំសំបត" . . . . . . . . . . ៥៤

វិទ្យុធម្មទេសនា កណ្ឌទី ៤

# លោកគ្រូអាចារ្យ មុញ-ន៉ាគ្រី

ក្រុមជំនុំព្រះត្រៃបិដក ក្រសួងពុទ្ធសាសនបណ្ឌិត្យ សំដែង

នៅថ្ងៃ ១៥ កើត ខែចេត្រ ឆ្នាំម្សាញ់ត្រីស័ក ព. ស. ២៤៨៤ (៣១ ម៉ារ្ស ឆ្នាំ ១៩៤២) ។

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

វេលានេះត្រូវវេនអាត្មាភាពសំដែងធម្មទេសនា ចែកជូនដល់អស់លោក-អ្នកទាំងឡាយ ដើម្បីជាសណ្តាប់ដូចសេចក្តីតទៅនេះ:

"មត្តញ្ញុតា សទា សាធុ"

"បុគ្គលអ្នកស្គាល់ប្រមាណរមែងញុំាងប្រយោជន៍ឲ្យសំរេចគ្រប់កាល"

ធម្មភាសិតនេះ សរសើរបុគ្គលអ្នកស្គាល់ប្រមាណថា អាចធ្វើប្រ-យោជន៍ឲ្យសំរេចបានគ្រប់កាល គ្រប់សម័យ ដូចសេចក្តីតទៅនេះ:

មត្តញ្ញុតា ភាពជាអ្នកស្គាល់ប្រមាណ គឺស្គាល់ថា ការធ្វើយ៉ាងនេះសម យ៉ាងនេះល្អ យ៉ាងនេះត្រូវទំនងចុះរបៀប ធ្វើយ៉ាងនេះសំរេចប្រយោជន៍ ។

ការស្គាល់ប្រមាណនេះ មានន័យគួរពណ៌នាបានដោយពិស្តារជាអនេក តែបើរើសស្រង់ប្រមូលមកទុកជាគោលមាន ៤ ប្រការគឺ:

១- ការដឹងប្រមាណក្នុងទ្រព្យសម្បត្តិ

២- ការដឹងប្រមាណក្នុងកិច្ចការ

៣- ការដឹងប្រមាណក្នុងការរក្សាកាយ

៤- ការដឹងប្រមាណក្នុងបុគ្គល

៥- ការដឹងប្រមាណក្នុងធម៌

## ទី ១ — ការដឹងប្រមាណក្នុងទ្រព្យសម្បត្តិ

ការដឹងប្រមាណក្នុងទ្រព្យសម្បត្តិ ចែកចេញដោយប្រភេទជា ៣ ប្រការ គឺ ស្គាល់ប្រមាណក្នុងការស្វែងរក ១, ស្គាល់ប្រមាណក្នុងការរក្សា ១ ស្គាល់ប្រមាណក្នុងការបរិភោគប្រើប្រាស់ ១ ។

ស្គាល់ប្រមាណក្នុងការស្វែងរក គឺចេះលៃលករកឧបាយក្នុងការស្វែងរកដែលត្រូវតាមគន្លងធម៌ មិនស្វែងរកដោយអាការកុហកករកូត បញ្ឆោត បោកប្រាស់បំបាត់ប្រវ័ញ្ចន៍ លួចប្លន់ដណ្ដើមអ្នកដទៃ ដោយកិច្ចកលចោរកម្ម មិនបន្លំដោយក្លែងជញ្ជីង តែកៀសបំផ្លាញដោយរង្វាល់នាឡិ តៅ-ក្ដាំង បំបិទបំបាំងបន្លាតបន្លិចទ្រព្យអ្នកដទៃ លៃយកចំណេញដោយឧបាយទុច្ចរិត ដែលខាត់ចូលក្នុងជំនួញប្រាំប្រការ ឬមន្ត្រីដែលលុះអំណាចអគតិធម៌ ស៊ីសំណូកសូកអង្វរសង្កត់កក្រ្តប្រជា ក៏ហៅថាការស្វែងរកមិនត្រូវគន្លងធម៌ដោយពិត ។

ការស្វែងរកដោយឧបាយទុច្ចរិត ត្រូវពុទ្ធទ្រង់ហាម ព្រោះជាហេតុធ្វើឲ្យអ្នកដទៃមានសេចក្ដីក្ដៅក្រហាយ ទឹងនាំឲ្យជួបប្រទះទៅលើទុក្ខទោសគ្រោះថ្នាក់ច្រើនប្រការ ឈ្មោះថាស្វែងរកសេចក្ដីទុក្ខមកដាក់ខ្លួនទឹងអ្នកដទៃ ទឹងបានសេចក្ដីវិនាសក្នុងលោកទាំងពីរ; ឯការស្វែងរកដោយឧបាយសុចរិត ជាហេតុនាំឲ្យត្រជាក់ចិត្តរបស់ខ្លួនទឹងអ្នកដទៃ នាំឲ្យទ្រព្យសម្បត្តិនិត្យនៅចំរុងចំរើនឡើងតាមលំដាប់ ។

ទ្រព្យសម្បត្តិដែលរកបានមកដោយយុត្តិធម៌យ៉ាងនេះ ត្រូវស្គាល់ប្រមាណក្នុងការរក្សាទ្រព្យថែមទៀត ព្រោះថាទ្រព្យសម្បត្តិដែលរកបានមកនោះ បើបុគ្គលបណ្ដែតបណ្ដោយប្រហែសធ្វេស ទឹងវិនាសបាត់បង់ទៅវិញដោយភ័យផ្សេងៗ មានចោរភ័យជាដើម នាំឲ្យបង់កម្លាំងខូចពេលវេលាដែលខំរកខំធ្វើមកហើយ ចួនកាលនាំឲ្យបង់ទ្រព្យដើមតាមរករបស់ដែលបាត់ទៅទ្វេគាតឡើងទៀត ហេតុនោះបុគ្គលម្ចាស់ទ្រព្យគួរតែប្រយ័ត្នក្នុងការថែរក្សាទ្រព្យសម្បត្តិឲ្យមុឺងម៉ាត់ ទើបបាត់ថាជាអ្នកស្គាល់ប្រមាណក្នុងការថែរក្សា ។ -

បុគ្គលដែលមានទ្រព្យសម្បត្តិ ឈ្មោះថាជាអ្នកមានសេចក្ដីសុខច្រើនប្រការ ព្រោះទ្រព្យសម្បត្តិអាចឲ្យសំរេចប្រយោជន៍ ៥ យ៉ាងគឺ:

១- ចិញ្ចឹមខ្លួន មាតាបិតា បុត្រភរិយា ទាសកម្មករឲ្យជាសុខ

២- ចងមិត្រសម្លាញ់ឲ្យជាសុខ

៣– សម្រាប់បំបាត់ភយន្តរាយដែលកើតអំពីហេតុផ្សេងៗ

៤– សម្រាប់ធ្វើពលិកម្ម ៥ ប្រការគឺ:

ក) ញាតិពលី ការសង្គ្រោះញាតិ

ខ) អតិថិពលី ការទទួលភ្ញៀវ

គ) បុព្វបេតពលី ការធ្វើបុណ្យឧទ្ទិសផលដល់អ្នកស្លាប់

ឃ) រាជពលី ការបង់ពន្ធស្ពួយសាអាករថ្វាយម្ចាស់ផែនដី

ង) ទេវពលី ការធ្វើបុណ្យឧទ្ទិសផលថ្វាយទេវតា

៥– បរិច្ចាគទានក្នុងសមណព្រាហ្មណ៍អ្នកប្រព្រឹត្តត្រូវ ។

ការបរិច្ចាគតាមដំណើរនេះ ចាត់ថាស្គាល់ប្រមាណក្នុងការបរិភោគប្រើប្រាស់ ។

មួយទៀត បុគ្គលដែលស្គាល់ប្រមាណក្នុងការប្រើប្រាស់ ចាយវាយទ្រព្យសម្បត្តិតាមកម្លាំងធនធានរបស់ខ្លួន ដឹងអស់ដឹងគង់ដឹងបង់ដឹងបាត់ មិនខ្ជះខ្ជាយតាមការឥតបទឥតសណ្តាប់ មិនបណ្តោយឲ្យទ្រព្យធនធ្លាក់ជ្រុះរោយរាយទៅដោយល្បែងពាលាគឺ: ល្បែងស្ត្រី ល្បែងស្រា កញ្ឆា អាភៀន ល្បែងភ្នាល់ផ្សេងៗ មានបៀ-ប៉ោ-ឆូ-អាប៉ោងជាដើម ក៏ចាត់ថាជាអ្នកស្គាល់ប្រមាណក្នុងការប្រើប្រាស់ចាយវាយ ។

មួយវិញទៀត បុគ្គលដែលចេះលៃលកប្រើតាមដំណើរទ្រព្យសម្បត្តិដែលតិចច្រើន មានសណ្ឋានតូចធំក្រាស់ស្តើង ផ្ទៀក់

វែងខ្លី ដាច់ស្រួយ រឹងទន់ ដែលគួរប្រើបានយ៉ាងណា សមរម្យ មិនមានគ្គង ប្រើយ៉ាងនោះ ក៏ចាត់ថាជាអ្នកស្គាល់ប្រមាណក្នុងការប្រើប្រាស់ ។

រួមការដឹងប្រមាណក្នុងការស្វែងរក ការរក្សានិងការប្រើប្រាស់ ឈ្មោះថាការដឹងប្រមាណក្នុងទ្រព្យសម្បត្តិ ។

## ទី ២ ការដឹងប្រមាណក្នុងកិច្ចការ

ធម្មតាកិច្ចការក្នុងលោក តែងមានសភាពផ្សេងៗគ្នា កិច្ចការខ្លះក្រលំបាក ខ្លះស្រួលងាយ ខ្លះតូច ខ្លះធំ ខ្លះយូរ ខ្លះឆាប់ តែកិច្ចការទាំងនោះ ទោះបីមានសភាពផ្សេងគ្នាជាអនេកប្បការយ៉ាងណាក៏ដោយ បើរួបរួមមកពណ៌នាដោយសង្ខេបមាន ២ យ៉ាងគឺៈ កិច្ចការដែលត្រូវធ្វើដោយកម្លាំងប្រាជ្ញា ១ កិច្ចការដែលត្រូវធ្វើដោយកម្លាំងកាយ ១ ។

វិជ្ជាអក្សរសាស្ត្រ លេខនព្វន្តគណហារ ហោរាសាស្ត្រ បរមត្ថវិជ្ជា ធម៌វិន័យត្រៃសិក្ខា ហៅថាកិច្ចការដែលត្រូវធ្វើដោយប្រាជ្ញា ។ កិច្ចការហត្ថកម្មសម្រាប់ជាងឈើ ជាងស៊ីម៉ង់ អ្នកស្រែអ្នកចម្ការ ដែលជាការត្រូវលើកលីពុនដញ្ជូនសែងរែកជាដើម ឈ្មោះថាកិច្ចការត្រូវធ្វើដោយកម្លាំងកាយ ។

និសម្មការណំ សេយ្យោ

កិច្ចការទាំងនោះ បុគ្គលត្រូវពិចារណាឲ្យឃើញជាក់លាក់ហើយ ទើបធ្វើល្អជាង ព្រោះថាអំពើដែលបុគ្គលធ្វើហើយ រមែងតាំងនៅប្រាកដអស់កល្បាវសាន ដូចជាគំនូសថ្មមិនងាយរលុបទៅវិញបាន ។

កតស្ស នត្ថិ បដិការំ

អំពើដែលបុគ្គលធ្វើជ្រុលហួសដោយកាយ វាចា ចិត្តមិនងាយកែប្រែបានទេ ប្រៀបដូចជាឆ្នាំងជាវិការនៃដី ដែលបែកហើយមិនដែលផ្សាភ្ជាប់វិញបានឡើយ ទុកណាជាផ្សាប៉ះប៉ុនបាន ក៏មិនមានរូបសណ្ឋានល្អដូចដើម ។

ន តំ កម្មំ កតំ សាធុ យំ កត្វា អនុតប្បតិ

អំពើណាដែលបុគ្គលធ្វើទៅហើយ ក្ដៅក្រហាយតាមក្រោយ អំពើដែលបុគ្គលធ្វើហើយនោះមិនប្រពៃឡើយ ។

អកតំ ទុក្កដំ សេយ្យោ

អំពើអាក្រក់បុគ្គលកុំធ្វើល្អជាង ។

ន ហិ តំ សុលភំ ហោតិ សុខំ ទុក្កដការិនា

បុគ្គលធ្វើអំពើអាក្រក់ មិនងាយបានសេចក្ដីសុខឡើយ ។

បុគ្គលអ្នកស្គាល់ប្រមាណគុណអំពើដែលខ្លួនធ្វើ ឈ្មោះថាដឹងប្រមាណគុណកិច្ចការ ។

## ទី ៣ ការដឹងប្រមាណក្នុងការរក្សារាងកាយ

រូបកាយរមែងជាទីស្រឡាញ់របស់ជនគ្រប់គ្នា ប៉ុន្តែខ្លះក៏ចេះរក្សារូបអាត្មាឲ្យបានសេចក្ដីសុខគ្រាន់បើ ខ្លះក៏ត្រឡប់ស្វែងរកសេចក្ដីទុក្ខមកបំពេញរាងកាយវិញ ៗ ព្រះឈ្មោះមារទ្រង់ត្រាស់ប្រដៅឲ្យរក្សារាងកាយដោយវិធីសំអាតភូមិភាគផ្ទះដី គេហដ្ឋាន គ្រឿងសំលៀកបំពាក់ អាហារសម្រាប់បរិភោគ ឲ្យជំរះមន្ទិល កោរសក់ពុកមាត់ កាត់ក្រចក សំអាតធ្មេញជាដើម ឲ្យលៃលកប្រើសំរិយាបថឲ្យស្មើ បរិភោគអាហារល្មមប្រមាណមិនឲ្យឃ្លានពានតាមចំណង់ តមអាហារដែលនាំឲ្យស្វែងដល់រាងកាយ មិនបរិភោគគ្រឿងស្រវឹងគ្រឿងពុល ដែលជាហេតុបណ្ដាលឲ្យកើតរោគដល់រាងកាយ ពីព្រោះរោគទាំងអស់មិនមែនសុទ្ធតែកើតមកអំពីផលកម្មទេ មានរោគខ្លះកើតឡើងព្រោះអាស្រ័យហេតុបច្ចុប្បន្ន ព្រះភគវន្តមុនីទ្រង់ត្រាស់សរសើរអំពីគុណនៃការរក្សារាងកាយថានាំឲ្យបានសេចក្ដីសុខ មានអាយុវែង ទើបទ្រង់សំដែងថាៈ . . .

សណ្ឋិតំ ជីវតិ អាយុំ ចាលុំ

អាយុដែលបុគ្គលរក្សា រមែងត្រាំត្រាទៅបន្តិចម្តងៗ ៗ រួមគេហៅថា ការដឹងប្រមាណក្នុងការរក្សារាងកាយ ៗ

# ទី ៤ ការដឹងប្រមាណក្នុងបុគ្គល

មនុស្សយើងដែលកើតឡើងក្នុងលោក សន្តានរមែងតែងឲ្យមានសភាពផ្សេងៗគ្នា: មានរូបកាយខុសគ្នា មានសន្ដានចិត្តមិនត្រូវគ្នា មាននាទីមុខក្រសួងកិច្ចការប្លែកគ្នា មានបុណ្យស័ក្តិខ្ពស់ទាបជាងគ្នា មានទ្រព្យធនធានតិចច្រើនជាងគ្នា ទាំងមានលទ្ធិសាសនាទំនៀមទម្លាប់ផ្សេងគ្នាទៀត; កាលបើមនុស្សមានសភាពផ្សេងៗគ្នាដូច្នេះហើយ ជាហេតុនាំឲ្យមានផ្លូវគិតជាអនេក ដល់បុគ្គលអ្នកនៅរួមគ្នា អ្នកអាស្រ័យទាក់ទងគ្នា; ហេតុនោះបុគ្គលត្រូវតែចេះលៃលកតម្រូវអធ្យាស្រ័យគ្នាទៅវិញទៅមក ដើម្បីរក្សាសេចក្ដីសុខឲ្យកើតមានសព្វខ្លួន, បានជាព្រះបរមសាស្ដាទ្រង់ប្រដៅគ្រហស្ថឲ្យតាំងនៅក្នុងឃរាវាសធម៌ ៤ ប្រការគឺ:

ទី ១ សច្ចៈ ឲ្យមានសេចក្ដីស្មោះត្រង់ចំពោះគ្នានឹងគ្នា ដើម្បីជាទីទុកចិត្តទៅវិញទៅមក គឺ: មាតាបិតា បុត្រធីតា ត្រូវសំដែងទឹកចិត្តស្មោះសរគ្នា ស្វាមីភរិយា ត្រូវសំដែងសេចក្ដីស្មោះស្ម័គ្រទៅវិញទៅមក មិនប្រព្រឹត្តកន្លងចិត្តគ្នា, ចៅហ្វាយនាយបាវព្រាវទៀតសោត ក៏ចេះសំដែងសេចក្ដីស្មោះត្រង់ដល់គ្នីគ្នា ។

២ ទមៈ ចេះទប់ចិត្តរបស់ខ្លួន ចេះទប់សំដីរបស់ខ្លួន ចេះបន្ទន់ចិត្តរកគ្នា មិនឲ្យកើតសេចក្ដីក្រោធបាន ចេះទូន្មានខ្លួននៅវេលាដែលមានឧបសគ្គចូលមកញាំញី ។

៣ ខន្តិ ឬ ធិតិ បើមានសេចក្តីក្រោធឡើងហើយ ចេះបង្ក្រាម ចេះបន្ទូយកំហឹងនោះទៅវិញ ចេះលុបលាងកំហុសមិនទទួលរំលើករឿងខុសមកពោលដដែលៗ ចេះលៃលករកឧបាយឲ្យស្ងប់សេចក្តីក្រោធ មិនព្យាបាទតអាឃាតចងពៀរគេទៅ ។

៤ ចាគៈ ចេះចែកចាយអាហារចំណីគ្រឿងឧបភោគបរិភោគដល់ គ្គ័គ្គា ។

យស្សេតេ ចតុរោ ធម្មា    សទ្ធស្ស ឃរមេសិនោ
សច្ចំ ធមោ ធិតិ ចាគោ    ស វេ បេច្ច ន សោចតិ ។

ធម៌ ៤ ប្រការគឺៈ សច្ចៈ ធមៈ ធិតិៈ ចាគៈ នេះ បើគ្រហស្ថឯណាមានជាប់ទៀងកាន់ប្រព្រឹត្ត គ្រហស្ថនោះនឹងមិនមានសេចក្តីទុក្ខព្រួយក្នុងលោកខាងមុខថែមទៀត ។ រួមមកហៅថា ការដឹងប្រមាណក្នុងបុគ្គល ។

## ទី ៥ ការដឹងប្រមាណក្នុងធម៌

ការដឹងប្រមាណក្នុងធម៌នេះ មានន័យគួរញែកអធិប្បាយជា ៣ យ៉ាងគឺៈ ដឹងប្រមាណក្នុងការរៀនសូត្រស្វាធ្យាយធម៌ ១ ដឹងប្រមាណក្នុងការសំដែងនិយាយពន្យល់ធម៌ ១ ដឹងប្រមាណក្នុងការប្រតិបត្តិធម៌ ១ ។

ការចេះលៃលកទន្ទេញស្វាធ្យាយពិនិត្យពិចារណាឲ្យបានចូលចិត្ត ជាក់លាក់ ចេះចាំប្រាកដស្ទាត់ជំនាញ ចាត់ជាស្គាល់ប្រមាណក្នុងការរៀនសូត្រ ។

សេចក្ដីឈ្លាសវៃក្នុងការសំដែងធម៌តាមដំណើរបរិសទ្យដែលចេះដឹង តិចច្រើន តាមឱកាសពេលវេលា ចាត់ជាស្គាល់ប្រមាណក្នុងការសំ-ដែងធម៌ ។

សេចក្ដីឈ្លាសវៃយល់ចំនងក្នុងការប្រព្រឹត្តិការកាន់តាម ដូចដឹងថា ទានត្រូវបរិច្ចាគយ៉ាងនេះ ទើបមានផលច្រើន, ឲ្យយ៉ាងនេះមានផលតិច; សីលត្រូវរក្សាដូច្នេះ ទើបបរិសុទ្ធ, កាន់ដូច្នេះសៅហ្មងពពាលពព្រុះ ដាច់ធ្លុះធ្លាយ; ភាវនាត្រូវចំរើនតាមរបៀបនេះ ទើបងាយសំរេចគុណតាមថ្នាក់ដែលគួរសំរេច ដូច្នេះជាដើមឈ្មោះថាស្គាល់ប្រមាណក្នុងការប្រតិ-បត្តិធម៌ ។

បុគ្គលអ្នកស្គាល់ប្រមាណក្នុងការប្រតិបត្តិធម៌ ទើបបានទទួលផលអំពីព្រះធម៌វិញ សមដូចព្រះលោកនាថទ្រង់ត្រាស់ថា:

ធម្មោ ហវេ រក្ខតិ ធម្មចារី ។

ព្រះធម៌រមែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌ (អ្នករក្សាធម៌) រីឯការដឹងប្រមាណក្នុងមាតិកាទាំង ៤ ដែលបានពណ៌នាដោយសង្ខេបមកនេះ ឈ្មោះថា "មត្តញ្ញុតា អ្នកស្គាល់ប្រមាណ" ។

បុគ្គលអ្នកដឹងប្រមាណ បាននាមថាជាសប្បុរស, បណ្ឌិត, អ្នកប្រាជ្ញ ខ្ទរទៅក្នុងលោក ។

ការដឹងប្រមាណ ចាត់ជាគុណធម៌មួយយ៉ាងវិសេសដែលគួរប្រាថ្នា ខានពុំបាន ព្រោះជាគុណញុំាងប្រយោជន៍ឲ្យសំរេចគ្រប់កាលគ្រប់សម័យ សមដូចពុទ្ធភាសិតដែលបានសាងទុកខាងដើមថា:

មត្តញ្ញុតា សទា សាធុ ៗ

អាចារ្យ ម៉ុញ - ឥ៉គ្រី